# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 781

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ធ្វើឲ្យប្រសើរឡើងនូវខ្សែច្រវ៉ាក់តម្លៃកសិចំណីអាហារប្រកបដោយចីរភាព តាមរយៈការ អភិវឌ្ឍកសិឧស្សាហកម្ម ក្នុងឧស្សាហកម្មទី៦

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | 01/01/26 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/28 |
| ៣. ចំណាយគម្រោងសរុប | $1,200,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| RESPONSIBLE UNIT | Department of Agro-Industry |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានកសិ-ឧស្សាហកម្ម |
| ៥. ស្ថានភាពគម្រោង | គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងវិនិយោគជាទុន |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ស្វែងរកម្ចាស់ជំនួយ |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអទិភាពខាងលើ គឺគម្រោងបានដើរ តួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែក ៖

- ជំរុញទីផ្សារផលិតផលកសិកម្មនិងកសិចំណីអាហារកម្ពុជាឲ្យមានភាពប្រសើរឡើងតាមរយៈការស្វែងរកទីផ្សារ ការប្រកួតប្រជែង និងទាក់ទាញ
- ជម្រុញ និងតម្រង់ទិសការវិនិយោគមកកម្ពុជា ដែលនឹងរួមចំណែកក្នុងការលើកកម្ពស់ការកែច្នៃផលិតផលកសិកម្ម និងកសិចំណីអាហារ
- បង្កើនប្រាក់ចំណូលដល់ប្រជាកសិករ និងប្រជាជនដោយផ្ទាល់ និងប្រយោល តាមរយៈការបង្កើតឱកាសការងារ និងប្រាក់ចំណូលទៀងទាត់
- ចូលរួមធ្វើឲ្យប្រសើរឡើងនូវការអភិវឌ្ឍសហគមន៍កសិកម្មទំនើប
- គ្រប់គ្រងទិន្នន័យផលិតផលកសិកម្ម កសិចំណីអាហារសម្រាប់វិស័យកសិ-ឧស្សាហកម្មមានភាពច្បាស់លាស់

ដែលគម្រោងនេះនឹងអនុវត្តស្របតាមយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលដែលបានដាក់ចេញក្នុងទិសដៅ បង្កើនសេដ្ឋកិច្ចជាតិប្រកបដោយបរិយាប័ន្នទូទាំងប្រទេស។

**១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា**

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍនវិស័យឧស្សាហកម្មកម្ពុជាដែរឬទេ?

មិនគាំទ្រ

**១១. វិស័យ** ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

**កសិកម្ម និងការគ្រប់គ្រងដីធ្លី** Land Management

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

**គ្រប់ខេត្តក្រុង,**

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

- ចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការស្វែងរកទីផ្សារសម្រាប់កសិករ បង្កើតឱកាសការងារ បង្កើនប្រាក់ចំណូលដល់កសិករ និងអ្នកពាក់ព័ន្ធ
- កាត់បន្ថយការបាត់បង់តម្លៃ និងគ្រប់គ្រងខ្សែច្រវ៉ាក់ផលិតកម្មកសិកម្មអោយកាន់តែប្រសើរឡើង
- គ្រប់គ្រងស្ថិតិ និងពត័មានផលិតផលកសិកម្ម ទីផ្សារ និងតម្រូវការអោយមានស្ថេរភាពតម្លៃកសិផល
- រក្សាលំនឹងនៃតុល្យភាពរវាងការផ្គត់ផ្គង់នឹងតម្រូវការទីផ្សារ
- លើកកម្ពស់ការគ្រប់គ្រងកសិពាណិជ្ជកម្មរបស់សហគមន៍កសិកម្ម
- បង្កើនសមត្ថភាពក្នុងការប្រកួតប្រជែងនិងតម្លៃបន្ថែមទៅលើផលិតផលកសិកម្មនៅលើទីផ្សារ និងធានាបាននូវគុណភាព សុវត្ថិភាពកសិ-ចំណីអាហារសម្រាប់ការនាំចេញ
- បង្កើតវេទិកាការផ្សរផ្គង និងផ្តល់ព័ត៌មានទីផ្សារ ដល់អ្នកផលិត និងវិនិយោគទុនលើវិស័យកសិកម្មនៅកម្ពុជា
- ជំរុញកំណើនសេដ្ឋកិច្ចជាតិ និងការប្រកួតប្រជែងពាណិជ្ជកម្មកសិកម្ម។

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

បុព្វហេតុនៃការបង្កើតគម្រោងនេះឡើង គឺបណ្តាលមកពីបញ្ហាជាច្រើនដែលមានក្នុងវិស័យកសិកម្មដូចជា៖
• ភាពមិនច្បាស់លាស់នៃទីផ្សារសម្រាប់លក់ផលិតផលកសិកម្ម
• ភាពនៅទន់ខ្សោយនៃកសិករ និងសហគមន៍កសិកម្ម លើការគ្រប់គ្រងបច្ចេកទេស និងកសិពាណិជ្ជកម្ម
• ព័ត៌មានអំពីទិន្នន័យផលិតផលកសិកម្មនៅមិនទាន់គ្រប់គ្រាន់ដែលធ្វើឲ្យពិបាកក្នុងការទាក់ទាញវិនិយោគទុន និងការកែច្នៃផលិតផលក្នុងស្រុក។

ដែលបញ្ហានេះយើងអាចដោះស្រាយបានគឺតាមរយៈកំណត់នូវសមាភាគនៃការអនុវត្តគម្រោងដូចខាងក្រោម៖
• សមាសភាគទី១៖ លើកកម្ពស់ខ្សែច្រវ៉ាក់តម្លៃផលិតកម្ម កែច្នៃ ស្តង់ដារគុណភាព និងសុវត្ថិភាព
• អនុសមាសភាគទី១.១៖ ពង្រឹងសក្តានុពលក្រុមផលិត និងសហគមន៍កសិកម្មបែបទំនើមប្រកបដោយបរិយាប័ន្ន
• អនុសមាសភាគទី១.២៖ គាំទ្រការគ្រប់គ្រងប្រព័ន្ធធានាគុណភាព សុវត្ថិភាព និងពង្រឹងខ្សែច្រវ៉ាក់តម្លៃនៃសហគ្រាសកែច្នៃ ដើម្បីរក្សាលំនឹង និងប្រកួងប្រជែងទីផ្សារ
• អនុសមាសភាគទី១.៣៖ ជំរុញការអនុវត្តបច្ចេកទេសក្រោយពេលប្រមូលផលប្រកបដោយសុវត្ថិភាព
• អនុសមាសភាគទី១.៤៖ ចុះស្រង់ទិន្នន័យអំពីផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម ព័ត៌មានទូទៅ និងបច្ចេកទេសផ្សេងៗ
• សមាសភាគទី២៖ គាំទ្រហេដ្ឋារចនាសម្ព័ន្ធ អភិវឌ្ឍន៍ធនធានមនុស្ស និងបច្ចេកវិទ្យាឌីជីថល
• អនុសមាសភាគទី២.១៖ កសាងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសិក្សាស្រាវជ្រាវ បច្ចេកទេសក្រោយប្រមូលផល ការកែច្នៃ និងពន្លឿនកសិពាណិជ្ជកម្ម
• អនុសមាសភាគទី២.២៖ គាំទ្រការអភិវឌ្ឍធនធានមនុស្ស និងបច្ចេកវិទ្យាឌីជីថល
• សមាសភាគទី៣៖ សម្របសម្រួលការផ្សារភ្ជាប់ទីផ្សារ និងលើកកម្ពស់កសិ-ធុរកិច្ច
• អនុសមាសភាគទី៣.១៖ រៀបចំវេទិការធុរកិច្ច ការប្រើប្រាស់យន្តការផ្សារភ្ជាប់ផលិតកម្មកសិកម្មនិងកសិចំណីអាហារ និងទីផ្សារ តាមរយៈយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា
• អនុសមាសភាគទី៣.២៖ ការលើកកម្ពស់ការប្រមូលផ្តុំ/បណ្តុំអាជីវកម្ម វេទិការកសិ-ធុរកិច្ច និងការផ្លាស់ប្តូរទីផ្សារក្រៅប្រទេស
• សមាសភាគទី៤៖ ការគ្រប់គ្រង ការសម្របសម្រួល តាមដាន និងត្រួតពិនិត្យគម្រោង

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

មូលហេតុដែលធ្វើឲ្យគម្រោងនេះត្រូវបានជ្រើសរើស គឺបណ្តាលមកពីបញ្ហាជាច្រើនដែលកើតមានក្នុងវិស័យកសិកម្មដូចជា
- ការរៀបចំយុទ្ធសាស្ត្រទីផ្សារសម្រាប់លក់ផលិតផលកសិកម្មជាចំនុចអតិភាពដែលត្រូវអនុវត្ត
- ការទាក់ទាញវិនិយោគទុន និងអ្នកកែច្នៃផលិតផលក្នុងស្រុកជាយុទ្ធសាស្ត្រចម្បង ដើម្បីឲ្យទីផ្សារកសិកម្មនៅកម្ពុជាមានការប្រសើរ ប្រកួតប្រជែង មានស្ថេរភាព និងកាត់បន្ថយពីការនាំចូលនៅផលិតផលពីខាងក្រៅ ដែលជំរុញដល់កំណើនសេដ្ឋកិច្ចជាតិឲ្យកាន់តែប្រសើរឡើងទៀតផង
- រក្សាលំនឹងនិរន្តភាពផលិតកម្មកសិកម្ម
- បង្កើនបរិមាណ និងគុណភាពនៃផលិតកម្មកសិកម្មសម្រាប់ផ្គត់ផ្គង់និងនាំចេញ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

- អ្នកដែលនឹងទទួលបានប្រយោជ៍ផ្ទាល់គឺប្រជាកសិករនៅតាមតំបន់ និងវិនិយោគទុន ដែលតាមរយៈការរៀនសូត្រ និងព័ត៌មានផ្តល់អំពីទីផ្សារច្បាស់លាស់។ តាមរយៈគម្រោងកម្មវិធី វាជាធាតុចូលមួយយ៉ាងសំខាន់ដែលមិនអាចខ្វះបានជាពិសេសសម្រាប់ កសិករ ពាណិជ្ជករ អ្នកវិនិយោគិន និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្ទាល់។ កសិករ សហគមន៏កសិកម្ម នឹងមានទីផ្សារលក់ផលិតផលកសិកម្មដែលមានស្ថេភាព ការគ្រប់គ្រងផលិតកម្ម និងតម្លៃ ឲ្យបានល្អទៅតាម តម្រូវការទីផ្សារ។ ពាណិជ្ជករ អ្នកវិនិយោគិននឹងអាចទទួលពត៌មានដែលជឿទុកចិត្តបាន នឹងអាចជាមូលដ្ឋានក្នុង ការសម្រេចចិត្តក្នុងការដាក់ទុនវិនិយោគលើផលិតផលកសិកម្ម និងអាចក្តាប់បាននូវទិន្នាការសក្តានុពលផលិតកម្មកសិកម្ម។ វីឯក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសនាយកដ្ឋានកសិឧស្សាហកម្ម នឹងទទួលបានទិន្ន័យផលិតផលកសិកម្ម តម្លៃទីផ្សារផលិតផល ដំណាំ និងតំបន់សក្តានុពលសម្រាប់ផ្សព្វផ្សាយ ដល់វិនិយោគិនក្នុងការអភិវឌ្ឍនវិស័យកសិឧស្សាហកម្ម ការកែច្នៃ។
- អ្នកដែលនឹងទទួលបានប្រយោជ៍ន៏មិនផ្ទាល់ គឺអង្គភាពផ្សេងៗដែលធ្វើការទាក់ទងនឹងកសិកម្ម។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**- គម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតាមជនបទ**
**តាមរយៈការជំរុញទីផ្សារលក់ផលិតផលកសិកម្មរបស់ពួកគាត់ បង្កើតឱកាសការងារជនបទ បង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ព្រមទាំង ការទទួលបាននូវចំនេះដឹងកាន់តែប្រសើរឡើងពីទីផ្សារកសិកម្មដែលធ្វើឲ្យជីវភាពរបស់ពួកគាត់កាន់តែប្រសើរឡើង។**
**- បង្កើនផលិតភាពកសិកម្ម តាមរយៈយន្តការខ្សែច្រវ៉ាក់ផ្គត់ផ្គង់ជាក់លាក់**
**- ក្នុងនោះផងដែលគម្រោងក៏បានចូលរួមចំណែកក្នុងកាត់បន្ថយភាពក្រីក្រទូទាំងប្រទេស**
**ព្រោះប្រជាជនមានជីវភាពកាន់តែល្អប្រសើរជាងមុន ព្រមទាំងបានកាត់បន្ថយការចំណាកស្រុករបស់ប្រជាពលរដ្ឋ**
**និងបានកាត់បន្ថយនៅការចំណាយសម្រាប់ទិញផលិតផលកសិកម្មពីខាងក្រៅ**
**និងធានាបាននូវសុវត្ថិភាពអាហារល្អប្រសើរជាងមុនតាមរយៈការគ្រប់គ្រងផលិផលកសិកម្មនៅក្នុងទីផ្សារ**
**ហើយក៏បានចូលរួមចំណែកក្នុងការបង្កើននៅសេដ្ឋកិច្ចជាតិផងដែរ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការបែងចែកយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**នៅក្នុងគម្រោងនេះមិនមានផលប៉ះពាល់អវិជ្ជមានដល់តួនាទីរបស់បុរស និងស្ត្រីទេ។ ព្រោះបុរស**
**និងស្ត្រីត្រូវបានផ្តល់សិទ្ធស្មើរៗគ្នាក្នុងការអនុវត្តគម្រោងនេះ ដោយគ្មានការរើសអើងអ្វីឡើយ។**
**ផ្ទុយទៅវិញសកម្មភាពទាំងអស់ស្ត្រីត្រូវបានលើកទឹកចិត្តឲ្យចូលរួម ទទួលការបណ្តុះបណ្តាល ទទួលព័ត៌មានពីទីផ្សារកសិកម្ម**
**ការដឹកនាំសកម្មភាព ផែនការប្រកបអាជីវកម្ម ការសិក្សាអំពីផលប៉ះពាល់ ការអភិវឌ្ឍន៏ និងសកម្មភាពនានាដូចបុរសដែរ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងពិតជាមានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោង**
**ព្រោះក្រសួងបានធ្វើការយ៉ាងជិតស្និតបំផុតជាមួយនឹងកសិករនៅតាមជនបទ**
**ហើយក្រសួងក៏មានអ្នកជំនាញបច្ចេកទេសដែលបានដើរជាតួរនាទីយ៉ាងសំខាន់ក្នុងការអនុវត្តគម្រោង។**

២៣. [illegible] អំពីភាពប្រឈមនានា ដែល បណ្តាល ឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

វឌ្ឍនភាពរបស់គម្រោងគឺជាការគ្រប់គ្រងដែលមានលក្ខណៈច្បាស់លាស់ ត្រឹមត្រូវ ព្រមទាំងមានការចូលរួមរបស់ប្រជាកសិករ សហគមន៍កសិកម្ម សហគ្រាសកសិកម្មនៅតាមតំបន់ និងវិនិយោគទុននៅក្នុងសកម្មភាពនានារបស់គម្រោង។ អំពីបញ្ហាប្រឈមនានា ដែលបណ្តាលឲ្យមានការពន្យាពេលក្នុងកាអនុវត្តគម្រោងគឺកង្វះខាតនៅការចូលរួមរបស់កសិករ និងថវិការសម្រាប់ការអនុវត្ត។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| ចំណាយប្រតិបត្តិ | 0.0 | 0.0 | 0.0 | 150.0 | 150.0 | 150.0 | 450.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 50.0 | 50.0 | 50.0 | 150.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 100.0 | 100.0 | 100.0 | 300.0 | 0.0 |
| | | | | | | | | |
| ចំណាយមូលធន | 0.0 | 0.0 | 0.0 | 250.0 | 250.0 | 250.0 | 750.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 100.0 | 100.0 | 100.0 | 300.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 150.0 | 150.0 | 150.0 | 450.0 | 0.0 |
| | | | | | | | | |
| ចំណាយសរុប | 0.0 | 0.0 | 0.0 | 400.0 | 400.0 | 400.0 | 1,200.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 400.0 | 400.0 | 400.0 | 1,200.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: